ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៨

ចុះថ្ងៃទី០៩ - ៦ - ១៩៩៨

សាលដីកា

លេខ : ១៦

ចុះថ្ងៃទី២៨ - ៧ - ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា កា រ កំ ពូ ល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក បោម សិរិវឌ្ឍ ចៅក្រម

៤ - លោក ព្រាក់ គឹមសាន ចៅក្រម

៥ - លោក ឃស់ សូខឿន ចៅក្រមរាយការណ៍

ក្រឡាបញ្ជី

លោក សាន សុផាត

តំណាងមហាអយ្យការ

លោក ប៉ែន សាវឿន ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៩៥ ចុះថ្ងៃទី០៨ - ៥ - ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ២៨ ចុះថ្ងៃទី ០៩ - ៦ - ១៩៩៨ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ ញឹក ផាន " ចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិរាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ - ញឹក ណៃ " រ " ម្តាយឈ្មោះស ឡាង " ស " ប្រពន្ធឈ្មោះខឹម ខឿន មានកូន០៣នាក់ ។

- មេធាវី គ្មាន

- ត្រូវចោទពីបទ : សម្លាប់មនុស្សដោយចេតនាមានអាវុធ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៧ - ០២ - ១៩៨០ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឈិន ទៀង " ម្ចាស់បណ្តឹងសាទុក្ខ " ភេទស្រី អាយុ៤៤ឆ្នាំ ជាតិខ្មែរ សព្វថ្ងៃនៅភូមិរាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

- មេធាវី លោក ហួន ជុនឌី

- តាមកំណត់ហេតុលេខ ៥៧ ចុះថ្ងៃទី ០៧ - ១០ - ១៩៩៦ របស់អយ្យការ អម តុលាការខេត្តកំពង់ស្ពឺ ថា នាងឈិនទៀង បានឆ្លើយថា កាលពីខែមិនចាំ ឆ្នាំ១៩៨០ ម៉ោងពេលល្ងាច ប្តីខ្លួនឈ្មោះ - អ៊ុង ទៀ មកពីធ្វើការនៅឃុំជង្រុក មកដល់ផ្ទះឈ្មោះ ទៀង ជុំ អ្នកនៅក្នុងផ្ទះលេងជាពួកដង្ហោយមាន

ប្ដីខ្លួនថាស្វាតាំហាស់សុំបាញ់មួយគ្រាប់ដើម ប្ដីខ្លួនក៏បាញ់មួយគ្រាប់ទៅលើ ។ មួយសន្ទុះឈ្មោះញ៉ឹក ផាន មកដល់កន្លែងបាញ់ហើយសួរថា អ្នកណាបាញ់អម្បាញ់មិញ ប្ដីខ្ញុំថា ខ្ញុំលោក ពេលនោះ ញ៉ឹក ផាន ថាបាញ់ហ្នឹងមានដឹងប្រជាជនឃើញឬទេ ។ ប្ដីខ្លួនថា ខ្ញុំបាញ់រួចហើយ ហើយញ៉ឹក ផាន ក៏បាញ់ប្ដីខ្លួនតែម្ដង អស់ចំនួនពីរគ្រាប់ ត្រូវត្រង់សៀតផ្កាភ្លេង ហើយមួយគ្រាប់ទៀតត្រូវត្រង់ទ្រូងធ្លាយទៅខ្នង ធ្វើអោយប្ដីខ្លួនដួលស្លាប់នៅនឹងកន្លែង ។ ពេល ញ៉ឹក ផាន បាញ់ប្ដីខ្លួនមានឈ្មោះ ឡុង អេត , ឡុង ភាព , តា នុំ ម្ចាស់ផ្ទះ និង ប៊ុង សឿង ជាអ្នកឃើញ ញ៉ឹក ផាន បាញ់ ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អម តុលាការខេត្តកំពង់ស្ពឺ ថា : ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយសាក្សី និង លិខិតបញ្ជាក់មរណភាព អយ្យការនៅតែរក្សាការចោទប្រកាន់ ព្រោះឈ្មោះ ញ៉ឹក ផាន នេះតុលាការពុំទាន់បានកាត់ទោសនៅឡើយទេ គ្រាន់តែសមត្ថកិច្ចបានឃុំខ្លួន រួចក៏ដោះលែងទៅ ។ ដូច្នេះសូមតុលាការសំរេចផ្ដន្ទាទោស ជនជាប់ចោទ ឈ្មោះ ញ៉ឹកផាន នេះទៅតាមច្បាប់ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៤ ចុះថ្ងៃទី ២០ - ៨ - ១៩៩៧ របស់តុលាការ ខេត្តកំពង់ស្ពឺ ដែលបានសំរេច :

១ - លើកលែងចោទប្រកាន់លើឈ្មោះ ញ៉ឹក ផាន ដោយឈ្មោះ ញ៉ឹក ផាន ត្រូវបានដោះលែង ជាស្ថាពរ តាមលិខិតស្នាមលេខ ចុះថ្ងៃទី ០៦ - ១២ - ១៩៩៤ រួចហើយចាប់ពីថ្ងៃនេះតទៅ ។

២ - អោយឈ្មោះ ញ៉ឹក ផាន សងជំងឺចិត្តដល់គ្រួសារជនរងគ្រោះឈ្មោះ ជិន ទៀង ចំនួន ២.០០០.០០០រៀល " ពីរលានរៀល " សំណើរលើសពីនេះបដិសេធចោល ។

៣ - អោយអភិបាលខេត្តកំពង់ស្ពឺប្រគល់ប្រាក់ ៥០០.០០០រៀល " ហាសិបម៉ឺនរៀល " អោយទៅឈ្មោះ ជិន ទៀង ចាប់តាំងពីថ្ងៃនេះតទៅ សំណើរលើសពីនេះបដិសេធចោល ។

៤ - សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះគូក្ដី បើកផ្លូវឧទ្ធរណ៍ពីរខែតាមច្បាប់កំណត់ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៥ ចុះថ្ងៃទី ២០ - ០៨ - ១៩៩៧ របស់ឈ្មោះ ជិន ទៀង ដែលប្ដឹងតវ៉ាពីសាលក្រមលេខ ៣៤ ចុះថ្ងៃទី ២០ - ៨ - ១៩៩៧ របស់តុលាការខេត្តកំពង់ស្ពឺ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា :

១ - ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ - ៨ - ១៩៩៧ របស់ដើមបណ្ដឹងឈ្មោះ ជិន ទៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២ - បដិសេធសាលក្រមលេខ ៣៤ ចុះថ្ងៃទី ២០ - ០៨ - ៩៧ របស់តុលាការខេត្តកំពង់ស្ពឺចោលជាអសាបង់ ។

៣ - សំរេចរំលត់បណ្ដឹងអាជ្ញាដោយផុតអាជ្ញាយុកាល លើឈ្មោះ ញ៉ឹក ផាន ពីបទ សម្លាប់មនុស្សដោយចេតនា ប្រព្រឹត្តនៅភូមិទាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១២ - ០២ - ១៩៨០ តាមប្រកាស " ត " នៃក្រិត្យច្បាប់លេខ ០២ករ ចុះថ្ងៃទី ១៥ - ៥ - ១៩៨០ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី ២៧ - ១១ - ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២០ - ៨ - ១៩៩៧ របស់ឈ្មោះ ឈិន ទៀង ទុកជាត្រឹមត្រូវតាមទំរង់ ដែលបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមលេខ ៣៤ ចុះថ្ងៃទី ២០ - ៨ - ៩៧ របស់តុលាការខេត្តកំពង់ស្ពឺទុកជាបានការ លើកលែងតែចំណុចទី១ ដែលសាលក្រមបដិសេធចោលហើយសំរេចជាថ្មីថា រំលត់បណ្តឹងអាជ្ញាលើឈ្មោះ ញឹក ផាន ពីបទចោទប្រកាន់ធ្វើមនុស្សឃាតដោយចេតនាតាមមាត្រា ៣៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅភូមិទាំង ឃុំជ្រង្គុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ - ០២ - ៨០ ។

៣ - សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ២១ ចុះថ្ងៃទី ១៨ - ៥ - ១៩៩៨ របស់អ្នកស្រីឈិន ទៀង ដែលប្តឹងពីសាលដីកាព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី ២៧ - ១១ - ១៩៩៧ របស់ សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី១៩ - ០៦ - ១៩៩៨ របស់អ្នកស្រី ឈិន ទៀង ផ្ញើទៅក្នុងកំណត់ច្បាប់ ។

- បានឃើញលិខិតបង្គាប់អោយឈ្មោះ ញឹក ផាន ចុងបណ្តឹងសាទុក្ខ ធ្វើសារណាតប ពីសារណារបស់អ្នកស្រី ឈិន ទៀង ហើយឈ្មោះនេះបានទទួលនៅថ្ងៃទី ២៣ - ១០ - ៩៨ រួចហើយប៉ុន្តែពុំបានឆ្លើយតបតាមកំណត់ច្បាប់ទេ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

១ - បណ្តឹងសាទុក្ខរបស់ឈ្មោះ ឈិន ទៀង ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៥៥ ចុះថ្ងៃទី ៨ - ៥ - ៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- បានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ឈិន ទៀង ថា : ឈ្មោះញឹក ផាន ពិតជាបានសំលាប់ប្តីនាងខ្ញុំមែន នាងខ្ញុំសុំអោយតុលាការមេត្តាជួយអោយរដ្ឋអំណាចថ្នាក់ខេត្ត ឬតុលាការខេត្ត ធ្វើជាអំណោយ ដល់ប្តីនាងខ្ញុំព្រោះគន្លងមកថ្នាក់ខេត្ត ស្រុក ធ្វើអំណោយដែរ តែនាងខ្ញុំពុំបានទទួលហើយតុលាការខេត្តសំរេច សំណងតិចតួចមិនសមនឹងអំពើរបស់ ញឹក ផាន សំលាប់ប្តីនាងខ្ញុំឡើយ ។

- តំណាងមហាអយ្យការ ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋានដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយដោះសារ របស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២១ ចុះថ្ងៃទី ១៨-៥-១៩៩៨ របស់អ្នកស្រី យិន ហៀង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថាបទល្មើសនេះកើតឡើងនៅថ្ងៃ ១២ ខែកុម្ភៈ ឆ្នាំ ១៩៨០ ហើយអយ្យការអមតុលាការខេត្តកំពង់ស្ពឺ ទើបតែធ្វើការចោទប្រកាន់ជនល្មើសឈ្មោះ ញ៉ឹក ផាន ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ១៩៩៧ ពីបទ ធ្វើមនុស្សឃាតដោយចេតនា មានអាវុធ ដូច្នេះបទល្មើសនេះប្រព្រឹត្តកន្លងទៅអស់រយៈពេលជាង ១៧ឆ្នាំ ហើយ ពុំមាននីតិវិធីតុលាការទៀត ឃើញថាការដែលឈ្មោះ ញ៉ឹក ផាន បានប្រព្រឹត្តកាលពីឆ្នាំ ១៩៨០ មកចោទប្រកាន់នៅឆ្នាំ១៩៩៧នោះគឺផុតអាជ្ញាយុកាល នៃបទល្មើសហើយ ។

- យល់ឃើញថា ទោះបីអាជ្ញាយុកាលនៃបទល្មើសបានកន្លងផុតទៅហើយក្ដី ប៉ុន្តែព្យសនកម្មដែលបណ្ដាលមកពីអំពើល្មើសមានពិតប្រាកដ ហើយដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានប្ដឹងតវ៉ាជាបន្តបន្ទាប់ដូច្នេះ តុលាការអាចសំរេចអំពីសំណងរដ្ឋប្បវេណី ។

- យល់ឃើញថា តុលាការថ្នាក់ក្រោមពុំបានសំរេចបង្គាប់អោយដាក់គុកបង្ខំដល់រូបកាយ ក្នុងករណីជនល្មើសនឹងរួសពុំព្រមសងប្រាក់ធនទណ្ឌដូច្នេះ តុលាការកំពូលសំរេចបន្ថែមដាក់គុកបង្ខំដល់រូបកាយតាមច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងករណីឈ្មោះ ញ៉ឹក ផាន នឹងរួសពុំព្រមសងប្រាក់ធនទណ្ឌគ្រប់ចំនួន ។

- យល់ឃើញថា ជនជាប់ចោទបានទទួលលិខិតបង្គាប់អោយធ្វើសារណាហើយ ប៉ុន្តែពុំបានធ្វើសារណាជូនមកតុលាការកំពូលទេដូច្នេះ តុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៩៥ ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១- ទទួលបណ្ដឹងសាទុក្ខលេខ ២១ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់អ្នកស្រី យិន ហៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹង គតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩៥ ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - បង្គាប់អោយដាក់គុកបង្ខំដល់រូបកាយតាមច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ក្នុងករណីជនល្មើសរឹងរូសពុំព្រមសងប្រាក់ធនទណ្ឌ ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៩ ។